

## កូនរបស់អ្នកត្រូវការពិនិត្យមើលជាតិសំណនៅក្នុងឈាម ប្រសិនបើពួកគេ ...

- ☐ រស់នៅឬក៏ខស្បាទៅលេងនៅក្នុងផ្ទះដែលសង់មុនឆ្នាំ1950?
- ☐ រស់នៅឬក៏ខស្បាទៅលេងនៅក្នុងផ្ទះដែលសង់មុនឆ្នាំ1978 ដែលថ្មីៗនេះត្រូវបានជួសជុលឬកែថ្មីឡើងវិញ?
- ☐ រស់នៅមណ្ឌលកុមារកំព្រា?
- ☐ មានមិត្តភ័ក្រឬក៏បងប្អូនបង្កើតដែលមានជាតិសំណរកំរិតខ្ពស់នៅក្នុងឈាម?
- ☐ មានឪពុកម្តាយឬអាណាព្យាបាលធ្វើការឬក៏ប្រកបការងារកំសាន្តនៅកន្លែងមានជាតិសំណ?
- ☐ មកពីប្រទេសផ្សេង ក្រៅពីប្រទេសអាមេរិក?
- ☐ ប្រើថ្នាំឬគ្រឿងសំអាងរបៀបជំនាន់ដើម?
- ☐ មានការធានារ៉ាប់រងមើលសុខភាពដោយ Apple Health/Medicaid (សូមមើលខាងក្រោម)?

### តើអ្នកបានឆ្លើយ បាទ/ចា៎ ឬក៏ ប្រហែល ទៅលើសំណួរទាំងអស់នេះដែរឬទេ?

សូមកាត់កាតនៅខាងក្រោមយកទៅ អោយគ្រូពេទ្យរបស់អ្នកនៅពេល ទៅពិនិត្យសុខភាពជាមួយគាត់នៅលើកក្រោយ។ ទទួលការពិនិត្យដោយឥតគិតថ្លៃពីគ្រូពេទ្យដែលទទួលយកប័ណ្ណមើលសុខភាពមេឌីខេដ Medicaid បើសិនជាកូនរបស់អ្នកមានការធានារ៉ាប់រងតាមរយ: Apple Health, ទោះបីជាកូនរបស់អ្នកគ្មានបញ្ហាអ្វីផ្សេងទៀតដ៏ដោយ។

# My child needs a blood lead screening test.

**កូនខ្ញុំត្រូវការពិនិត្យមើលជាតិសំណនៅក្នុងឈាម។**

Washington State Department of Health

Public Health
Seattle & King County

## មូលហេតុអីបានកូនរបស់ខ្ញុំពិគ្រូនិត្យមើលជាតិសំណនៅក្នុងឈាម?

ទោះបីជាមានជាតិសំណបន្តិចបន្តួចក៏ដោយក៏អាចបណ្ដាលអោយខួរក្បាលកូនរបស់អ្នកខូះខាតការលូតលាស់ដែរ។ បើសិនជាតិសំណរចូលទៅក្នុងខ្លួនកូនរបស់អ្នក វាអាចបណ្ដាលអោយកូនរបស់អ្នករៀនមិនចេះ, ពិបាកយកចិត្តទុកដាក់, ហើយរៀនមិនទាន់គេ។

## តើការពុលជាតិសំណមានអាការៈដូចម្ដេចខ្លះ?

កូនក្មេងភាគច្រើនដែលមានជាតិសំណនៅក្នុងខ្លួនរបស់ពួកគេអត់មានអាការៈឈឺស្កាត់ទេ។ មានតែការពិនិត្យមើលឈាមតែប៉ុណ្ណោះដែលអាចដឹងថាកូនរបស់អ្នកពុលនិងជាតិសំណ។

## អ្វីខ្លះដែលបណ្ដាលអោយពុលនិងជាតិសំណ?

ធូលីលាយជាតិសំណហើយនិងកំទេចចេញពីជាតិថ្នាំនៅតាមផ្ទះចាស់ៗគឺជាប្រភពដ៏ធំបំផុតនៃជាតិពុលនេះ។ ធូលីលាយជាតិសំណអាចប្រឡាក់ដៃនិងរបស់ក្មេងលេង។ ពេលពួកគេដាក់ដៃ ឬរបស់លេងចូលក្នុងម៉ាត់, ពួកគេលេបជាតិសំណនោះចូលក្នុងពោះ។ របស់ផ្សេងៗទៀតដែលអាចបណ្ដាលអោយពុលនិងជាតិសំណគឺ:



ធូលីនិងទឹក



ផ្លាស្ទីក, ល្បែងក្មេងលេងចាស់ៗ, ហើយនិងកូនសោរ



ឆ្នាំងដីធ្វើដោយខ្លួនឯងឬក៏ចានបាយ



គ្រឿងសំអាងនាំចូលពីប្រទេសក្រៅ ឬគ្រឿងដាំស្ល

ចំពោះពត៍មានបន្ថែមអំពីជាតិសំណរហើយនិងផែកមើលភពដែលអាចបណ្ដាលអោយមានជាតិសំណរនៅក្នុងភូមិរបស់អ្នក សូមចូលមើលគេហទំពរ www.doh.wa.gov/lead

**Provider: The State DOH lead risk factor questionnaire identified this child as having one or more risk factors for lead exposure.**

**Federal law mandates** that all children enrolled in Medicaid are required to get blood lead screening tests at ages 12 and 24 months. Any child between 24 and 72 months with no record of a previous blood lead screening test must receive one.

For more information visit: **www.doh.wa.gov/lead**